# ការងារបច្ចេកទេសសំណង់និងតារាងសម្ភារៈ
# នៃការងារជួសជុលអគារសិក្សា

**តារាងមាតិការ** **ទំព័រ**


1 **សេចក្ដីផ្ដើម** ........ 2

2 **ការងារជួសជុលទ្វារបង្អួចឈើ** ........ 3

3 **ការងាររៀបប្លុកជញ្ជាំងឥដ្ឋ** ........ 3

4 **ការងារលាបថ្នាំជញ្ជាំង** ........ 4

4.1 ការងារខាត់សម្អាត ........ 4

4.2 ការងារម្សៅបៀក ........ 5

4.3 ការងារលាបថ្នាំទ្រនាប់ ........ 5

4.4 ការងារលាបថ្នាំបញ្ចប់ ........ 5

5 **ការងារពិដាន** ........ 6

6 **ការងារការ៉ូ** ........ 6

7 **ការងារកញ្ចក់** ........ 7

8 **ការងារប្រព័ន្ធអគ្គិសនី** ........ 7

# ការងារបច្ចេកទេសសំណង់

## 1 សេចក្តីផ្តើម

ក្នុងឯកសារនេះចង់បង្ហាញពីការងារបច្ចេកទេស និងសេចក្តីលម្អិតនៃការងារជួសជុលអគារថ្នាក់រៀន របស់កម្មវិធីសាលារៀនជំនាន់ថ្មី។ ជាក់ស្តែងការងារនេះគឺជាការងារជួសជុល លើអគារសិក្សាចាស់ដែលមានស្រាប់ ហើយការងារដែលត្រូវធ្វើនៅពេលនេះមានដូចជា ការងារជួសជុលជញ្ជាំងចាស់ ខាត់សម្អាតនិងលាបថ្នាំថ្មី ការងារជួសជុលលាបថ្នាំបង្អួចឈើ ប្រព័ន្ធអគ្គិសនី ការងារក្រាលការ៉ូ និងការងារបង្អួចទ្វារកញ្ចក់ជាដើម។



Figure 1 អគារដែលត្រូវជួសជុល នៅវិទ្យាល័យព្រះអង្គឌួង



Figure 2 អគារដែលត្រូវជួសជុលនៅអនុវិទ្យាល័យ អរញ្ញរង្សី

## 2 ការងារជួសជុលទ្វារបង្អួចឈើ

ការងារទ្វារបង្អួចឈើត្រូវជួសជុលដោយកោសឬខាត់ថ្នាំចាស់កំទេចធូលីដីនិងស្នាមប្រឡាក់ផ្សេងៗ និងលាបឬបាញ់ថ្នាំឡើងវិញ។ បង្អួចនិងទ្វារជាបង្អួចទ្វារឈើធម្មជាតិ ស្លាបព្រិល។ ទ្វារមានមួយសន្លឹក និងបង្អួចមាន ៤សន្លឹក និង ពីរសន្លឹកក្នុងមួយគ្រោង។ ត្រូវដាក់បន្ថែមគ្រឿងមួយចំនួនដែលខូចខាត ដូចជា ត្រចៀក គន្លឹះ ជន្ទល់ ជាដើមទៅតាមការងារខូចជាក់ស្តែង។

## 3 ការងាររៀបប្លុកជញ្ជាំងឥដ្ឋ

ការងារជញ្ជាំងឥដ្ឋមានពីរប្រភេទគឺ ជញ្ជាំងឥដ្ឋ ១០០mm និងជញ្ជាំងឥដ្ឋ ២០០mm។ សម្រាប់ជញ្ជាំងឥដ្ឋ ២០០ ត្រូវរៀបនៅជញ្ជាំងខាងក្រៅជុំវិញអាគ្គាទាំងអស់លើកលែងលើធ្នឹមឡាំងតូ។ ចំពោះឥដ្ឋ ១០០ ត្រូវរៀបផ្នែកខាងក្នុង និងខាងលើធ្នឹមឡាំងតូ។ ការងាររៀបទាំងឥដ្ឋ ១០០និង ឥដ្ឋ ២០០ ត្រូវរៀបឥដ្ឋតាន់នៅជើងក្រោមជញ្ជាំងចំនួន ៣ ស្រទាប់ និងរៀបឥដ្ឋតាន់មួយស្រទាប់រៀងរាល់កម្ពស់ 0,5ម ម្តង ហើយត្រូវរៀបឥដ្ឋតាន់ផ្តេកមុំ 45ដឺក្រេនៅខាងលើ

ទល់នឹងផ្ទឹម នៅគ្រប់ជញ្ជាំងទាំងអស់។ ចំពោះការងារជញ្ជាំងបន្ទប់ទឹកត្រូវរៀបឥដ្ឋតាន់ជើងក្រោម៥ស្រទាប់។ សម្រាប់ការងារបូកសម្អាតជញ្ជាំងត្រូវធ្វើលើជញ្ជាំងមានស្រាប់និងជញ្ជាំងរៀបថ្មី ហើយត្រូវបូកកម្រាស់ 15 ទៅ 20 មម។

- ត្រូវសម្អាតកន្លែងដែលត្រូវរៀបអោយបានស្អាត និងដៅអ័ក្សជញ្ជាំងអោយបានត្រឹមត្រូវ។
- ត្រូវរៀបរន្ទាសម្រាប់ជញ្ជាំងដែលមានទីតាំងខ្ពស់
- ចាប់ផ្តើមការងាររៀបឥដ្ឋ ដោយរៀបឥដ្ឋតាន់បីស្រទាប់នៅជើងក្រោម និងមួយស្រទាប់រាល់0,5មម្តង។
- ចាប់ផ្តើមការងារបូកសម្អាតឲ្យបានស្អាតនិងស្មើល្អនិងបាញ់ទឹកថែទាំទៅតាមបច្ចេកទេស។
- សមាសភាពសម្ភារៈដែលត្រូវប្រើសម្រាប់ការងាររៀបបូក

| សមាសធាតុក្នុងមួយម៉ែត្រគូប | | | |
|---|---|---|---|
| កម្លាំងបាយអរ (MPa) | ស៊ីម៉ងត៍ (Kg) | ខ្សាច់ (Kg) | ទឹក (L) |
| 7.5 | 313 | 1773 | 285 |
| ឬតាមផលធៀប | 1បាវ | 8 ធុង (20L) | |

## 4 ការងារលាបថ្នាំជញ្ជាំង

ការងារងារលាបថ្នាំជញ្ជាំងមានពីរប្រភេទ គឺលាបផ្នែកខាងក្នុងនិងខាងក្រៅ ហើយការងារនេះត្រូវបានចែកជាបួនដំណាក់កាលគឺៈ ការងារកោសឬខាត់ថ្នាំចាស់ ការងារម្សៀបៀក Skim Coat ការលាបថ្នាំទ្រនាប់ ការលាបថ្នាំបញ្ចប់ ចំពោះផលិតផលត្រូវជ្រើសរើសតាមលក្ខ័ណដែលបានដាក់ជូន។ ចំពោះវិធីសាស្ត្រនៃការងារថ្នាំជញ្ជាំងមានដូចជាៈ

### 4.1 ការងារខាត់សម្អាត

- ជញ្ជាំងដែលត្រូវលាបថ្នាំត្រូវខាត់សម្អាតដោយប្រើ ម៉ូទ័រខាត់ផ្លែសំណាញ់ដែក ឬកាំបិតឈូស និងក្រដាស់ខាត់ទៅតាមការងារជាក់ស្តែង និងបោសសម្អាតលាងទឹករួចទុកអោយស្ងួត ឬប្រើម៉ាស៊ីនបាញ់ខ្យល់ដើម្បីសម្អាត។
- លើផ្ទៃដែលត្រូវបៀកត្រូវតែស្អាត និងគ្មានសារជាតុគីមី ដូចជា ស្នាមប្រឡាក់ប្រេង ធូលីខ្លាញ់និងសារជាតុផ្សេងៗទៀត និងមានសំណើម 85% និងសីតុណ្ហភាពមិនក្រោមពីបីដឺក្រេ។
- រន្ធ ចន្លោះប្រហោងផ្សេងៗនៃការងារប្រព័ន្ធទឹកភ្លើងត្រូវបិតអោយជិតមុនការងារបៀកចាបើផ្តើម។

- ផ្ទៃនៃជញ្ជាំងមិនត្រូវមានស្នាមប្រេះ ហើយត្រូវជួសជុលឡើងវិញរាល់មុខដំណរ ឬបញ្ហាផ្សេងៗនៅលើជញ្ជាំងអោយបានរួចរាល់មុននឹងចាប់ផ្តើមការងារថ្នាំ។

### 4.2 ការងារម្សៅបៀក

- ការងារជញ្ជាំងត្រូវបញ្ចប់អោយបាន ១០០% ហើយបាយអរបូកត្រូវមានអាយុមិនក្រោម ២៨ ថ្ងៃមុនការងារបៀកត្រូវចាប់ផ្តើម
- ការងារជញ្ជាំងត្រូវធ្វើយ៉ាងណាអោយផ្ទៃត្រង់ និងស្មើបានល្អ ដែលកម្រាស់អាចប្រែប្រួលពី 1មម ទៅ 3មម និងអាចអនុញ្ញាតធំបំផុតបានត្រឹម 5មម ប៉ុណ្ណោះ។ ត្រូវទុកការងារនេះអោយបានយ៉ាងតិច ២៤ម៉ោងដើម្បីអោយស្ងួតល្អមុននឹងចាប់ផ្តើមការងារថ្មី។
- ត្រូវខាត់សម្អាតនិងចាប់ជ្រុង អោយបានស្អាតនិងមានផ្ទៃរាបស្មើ។

### 4.3 ការងារលាបថ្នាំទ្រនាប់

- បន្ទាប់ពីការងារបៀកជញ្ជាំងត្រូវបានធ្វើរួចរាល់ និងពិនិត្យទៅតាមបទដ្ឋានបច្ចេកទេស ការងាររុញថ្នាំទ្រនាប់ត្រូវបានចាប់ផ្តើមៈ
- ត្រូវធានាថា ផ្ទៃជញ្ជាំងដែលបានបៀកដោយម្សៅបៀកសម្អាតបានស្អាត គ្មានធូលី និងកំទេចកំទីផ្សេងៗ
- រុញថ្នាំទ្រនាប់ជាមួយនឹងរូឡូដែលស្អាត ដែលមិនធ្វើអោយមានផលប៉ះពាល់ដល់ផ្ទៃជញ្ជាំង
- ស្រទាប់ថ្នាំទ្រនាប់ត្រូវអនុញ្ញាតិអោយរុញបានតែមួយស្រទាប់ប៉ុណ្ណោះ ហើយរក្សាទុករយៈពេល ១,៥ ម៉ោងបន្ទាប់ពីរុញថ្នាំទ្រនាប់រួច មុនពេលអនុញ្ញាតិអោយរុញថ្នាំពណ៌។

### 4.4 ការងារលាបថ្នាំបញ្ចប់

- ការងារថ្នាំចុងបញ្ចប់ គឺជាប្រភេទការងារដែលត្រូវយកចិត្តទុកដាក់ ទាំងផ្នែកគុណភាពនិងសោភ័ណ្ឌភាព ហើយការជ្រើសរើសថ្នាំយកមកប្រើមានពីរប្រភេទគឺផ្នែកខាងក្នុងនិងខាងក្រៅៈ
- ការជ្រើសរើសថ្នាំដោយកំណត់លេខកូដត្រូវធ្វើជាចាំបាច់មុននឹងទិញមកប្រើប្រាស់
- ត្រូវប្រើរូឡូឬជក់ដែលមានលក្ខណៈទន់ ដែលធ្វើឲ្យទឹកថ្នាំមានលក្ខណៈរលោងនិងស្មើសាច់
- ត្រូវរុញថ្នាំពណ៌ដោយស្រទាប់ស្តើងៗច្រើនដង ជាជាងការរុញដោយកម្រាស់ក្រាស់យកតែម្តង
- ចំពោះការុញស្រទាប់ថ្នាំនិមួយៗត្រូវរក្សាទុករយៈពេលយ៉ាងតិច ២ម៉ោងមុននឹងចាប់ផ្តើមស្រទាប់ថ្នាំថ្មី។

| ពិពណ៌នា | ប្រភេទផលិតផល | ចំនួនស្រទាប់ |
|---|---|---|
| បៀកម្សៅបៀក (Skim Coat) | ម្សៅបៀកម៉ាក CamStar (សញ្ញាផ្កាយ) original | 2 ទៅ 3 |
| លាបថ្នាំស្រទាប់ការពារ | ថ្នាំទ្រនាប់ Sealer Protan | 1 |
| លាបថ្នាំស្រទាប់បញ្ចប់ខាងក្រៅ | (CamPaint Vital **Code N3399**) | 2 |

| | | |
|---|---|---|
| លាបថ្នាំស្រទាប់បញ្ចប់ខាងក្នុង | ( Campaint Vital White ) | 2 |

## 5 ការងារពិដាន

- នៅក្នុងអគារនេះពិដានដែលត្រូវជ្រើសរើសយកមកប្រើគឺ ជាពិដានម្នាងសិលាលាត ដូចមានភ្ជាប់ជូនក្នុងប្លង់។ សន្លឹកពិដានដែលយកមកប្រើប្រាស់នេះចែកជាពីប្រភេទគឺ ប្រើសន្លឹកពិដានម្នាងសិលាធម្មតាសម្រាប់ក្នុងបន្ទប់ និងសន្លឹកពិដានការពារសំណើមសម្រាប់ពិដាននៅបន្ទប់ទឹក។ ការងារពិដានត្រូវតម្លើងទៅតាមដំណាក់កាលដូចតទៅៈ
- មុនពេលចាប់ផ្តើមការងារពិដានត្រូវប្រាកដថា អគារទាំងមូលត្រូវមានភាពស្ងួត
- រាល់ប្រព័ន្ធភ្លើង បំពង់ដែលស្ថិននៅក្នុងពិដាន ត្រូវតែបញ្ចប់រួចរាល់មុនពេលការងារពិដានចាប់ផ្តើម
- ត្រូវដាក់ខ្សែបន្ទាត់ដែលជានីវ៉ូរបស់ពិដាននៅលើជញ្ជាំងដើម្បីត្រួតពិនិត្យនូវផលប៉ះពាល់ផ្សេងៗ ដូចជាប្រព័ន្ធ MEP ជាដើម
- ប្រភេទឆ្អឹងពិដានដែលយកមកប្រើគឺ ឆ្អឹង C-line ដែលមានកម្រាស់ 0,27 មម
- តម្លើងឆ្អឹងពិដានដោយអនុវត្តគម្លាតស្តង់ដា 400មមx600មម និងត្រូវបន្ថែមឆ្អឹងពង្រឹងក្នុងករណីចាំបាច់
- ត្រូវត្រួតពិនិត្យបញ្ហាផ្សេងៗមុននឹងអនុញ្ញាតិអោយបិតសន្លឹកពិដាន
- បិទសន្លឹកពិដានភ្ជាប់ទៅនឹងឆ្អឹងពិដាន ដោយប្រើប្រាស់វីសខ្មៅសម្រាប់សន្លឹកពិដាន
- ត្រូវធានាថាសន្លឹកពិដានត្រូវបានបិទជាប់ល្អជាមួយនឹងឆ្អឹង នីវ៉ូត្រឹមត្រូវ និងត្រង់ស្មើល្អមិនប៉ោង ឬផត ដោយប្រើវីសចន្លោះ 150មម នៅចុងសន្លឹក និងចន្លោះ 240មម នៅកណ្តាល
- មុខដំណរសន្លឹកពិដានត្រូវបិតដោយស្កុតសំណាញ់ ( Joint Tape ) និងប្រើប្រាស់ម្សៅបៀកដើម្បីធ្វើឲ្យមុខដំណរមានភាពស្មើល្អ ក្បាលវីសក៏ត្រូវបៀកម្សៅដូចគ្នាដើម្បីលុបនៅពេលលាបថ្នាំ
- បន្ទាប់ពីបៀកម្សៅមុខដំណរនិងក្បាលវីសរួចហើយត្រូវទុកអោយស្ងួតនិងខាត់អោយបានស្មើស្អាត
- ត្រូវរុញថ្នាំទ្រនាប់ (Sealer) មួយស្រទាប់ រួចទើបលាបថ្នាំពិដានចុងបញ្ចប់។

## 6 ការងារការ៉ូ

- ការងារការ៉ូត្រូវបានចែកជាពីរប្រភេទគឺ ការ៉ូបាតនៅក្នុងអគារ និងខាងក្រៅអគារ និងជើងជញ្ជាំងក្នុងបន្ទប់។
- មុនចាប់ផ្តើមការងារការ៉ូ ត្រូវត្រួតពិនិត្យផ្ទៃដែលត្រូវរៀបនិងរៀបចំអោយបានស្អាត រាល់ចន្លោះតូចៗនៅលើផ្ទៃត្រូវតែបិតអោយជិត។
- មុនពេលរៀបត្រូវហែកការ៉ូចេញពីកេះនិងត្រួតពិនិត្យលើពណ៌និងស្នាមប្រេះ រាល់ការ៉ូដែលមានប្រេះឬបែកមិនអនុញ្ញាតិអោយរៀបជាដាច់ខាត។
- វាស់ដាក់ខ្សែបន្ទាត់អោយបានត្រឹមត្រូវមុននឹងចាប់ផ្តើមការងាររៀប។
- សម្ភារះមាន ស៊ីម៉ង់ត៍ ខ្សាច់ទន្លេ Bonding Agent ទឹកស្អាត ម្សៅបៀករ៉ង ការការ៉ូ។

- មុនពេលរៀបការ៉ូត្រូវតែស្អាត បន្ទាប់មក **Slurry Bonding Agent** ដែលបានលាយរួចត្រូវតែលាបលើផ្ទៃប្លង់សេដែលបានសម្អាតរួច។
- លាយការការ៉ូជាមួយទឹកស្អាតទៅតាមភាគរយនៃសមាសភាពដែលបានកំណត់ទៅតាមប្រភេទផលិតផល។
- លាបការការ៉ូលើប្លង់សេដែលបានក្រាលដោយបាយអរ ហើយប្រើស្លាបព្រាមានធ្មេញរណារគៀរអោយស្មើល្អ។
- ក្រាលការ៉ូថ្មមៗអោយត្រូវជ្រុងល្អតាមខ្សែបន្ទាត់រួចយកញញួរមកវ៉ៃថ្មមៗអោយស្មើល្អ។
- ជូតសម្អាតរាល់ការដែលលើស និងប្រើប្រាស់រង់ជ័រការ៉ូត្រង់ចំណុចគែមនៃការ៉ូដែលបានរៀបរួច និងបន្តរៀបតាមខ្សែបន្ទាត់ ហើយត្រូវដាក់ការអោយពេញមិនត្រូវអោយមានខ្យល់នៅត្រង់ចំណុចណាមួយនៃផ្ទៃការ៉ូឡើយ។
- នៅពេលការ៉ូរៀបបានផ្ទៃមួយម៉ែត្រការេត្រូវត្រួតពិនិត្យនៅលើភាពត្រង់ទៅតាមទិស X,Y និងនីវ៉ូផ្ទៃត្រូវតែធ្វើព្រោះវាជាចំណុចចាប់ផ្តើមនាំការរៀបការ៉ូ។
- រង់ការ៉ូអាចអនុញ្ញាតិនៅចន្លោះពី ១ មមទៅ២មម ប៉ុណ្ណោះ។
- ការលាយបាអរសម្រាប់រៀបត្រូវប្រើល្បាយផលធៀប ១/៤ (ស៊ីម៉ង់ត៍ ១ ខ្សាច់ ៤)

| | | |
|---|---|---|
| ល្បាយបាយអររៀបការ៉ូ | ស៊ីម៉ង់ត៍ | ខ្សាច់ |
| | 1 | 4 |
| ល្បាយ Slurry Bonding Agent | Planicrete SP | Portland Cement |
| | 1 | 1 |

## 7 ការងារកញ្ចក់

- ការងារកញ្ចក់ដែលបានដាក់នៅក្នុងគម្រោងនេះមានដូចជា បង្អួចកញ្ចក់កម្រាស់ ៨មមធ្នឹងអាលុយមីញ៉ូមពណ៌**ស សន្លឹករុញស្លាយកង់ភ្លោះ** និងទ្វារកញ្ចក់**ចំហុយ** Tempered Glass Door ពីរសន្លឹករួមទាំង ដៃទ្វារសោរ និងត្រ**ចៀក**អូតូ ម៉ាក VVP ថៃ។ ធ្នឹងអាលុយមីញ៉ូមត្រូវប្រើពណ៌**ស**កម្រាស់ ១,២មម។ **ចំពោះការងារ**តម្លើងទ្វារត្រូវធ្វើអោយបានត្រឹមត្រូវទៅតាមលក្ខណៈបច្ចេកទេស។ ប្រភេទទ្វារកញ្ចក់ **Tempered Glass Door** ពីរសន្លឹក ឬមួយសន្លឹកទៅតាមការងារជាក់ស្តែង។
- ចំពោះទ្វារត្រូវប្រើត្រចៀកជុំអូតូម៉ាក **VVP** ផលិតផលថៃ ចាប់សោរខាងក្រោម ហើយជើងក្រោមទ្វារត្រូវទុកចន្លោះ ១០មម ពីនីវ៉ូការ៉ូ។
- ការចាប់គ្រោងទ្វារត្រូវធ្វើឡើងអោយបានត្រឹមត្រូវ ដោយវាស់មុំ ៩០ដឺក្រេ។
- គ្រោងទ្វារត្រូវចាប់និងស្វានចូលដោយដែកអោយបានត្រឹមត្រូវនឹងរឹងមាំល្អ។

## 8 ការងារប្រព័ន្ធអគ្គិសនី

ការងារប្រព័ន្ធអគ្គិសនីខាងក្នុងអគារត្រូវធ្វើទៅតាមលក្ខណៈស្តង់ដាបច្ចេកទេសនៃការងារអគ្គិសនី ហើយចែកចេញជាផ្នែកៗដូចខាងក្រោមៈ

### 8.1 ការងារអំពូលភ្លើង

ការងារអំពូលភ្លើងត្រូវប្រើអំពូលបង្កប់លើពិដាន Down light និងអំពូលម៉ែត្រ LED នៅខាងក្រៅសូមមើលតារាងសម្ភារៈនិងប្លង់។ចំពោះខ្សែដែលរាយលើពិដានត្រូវប្រើគែនសម្រាប់ស្រោបការពារខ្សែតាមលក្ខណៈបច្ចេកទេស។

### 8.2 ការងារព្រីភ្លើង

ការងារព្រីភ្លើងចាប់បណ្តែតជាប់ជញ្ជាំងជាប្រភេទព្រីទេរ ត្រូវបង្កប់ជាប់លើជញ្ជាំង ដោយប្រើទុយោភ្លើងស្រោបខ្សែតាមលក្ខណៈបច្ចេកទេស។

### 8.3 ការងារម៉ាស៊ីនត្រជាក់

ការងារម៉ាស៊ីនត្រជាក់ចាប់លើជញ្ជាំងអាចមាននៅក្នុងបន្ទប់មួយចំនួន ដូចជាបណ្ណាល័យ និងការិយាល័យមួយចំនួន។ ម៉ាស៊ីនត្រជាក់ដែលយកមកប្រើគឺម៉ាក Panasonic Invertor ស៊េរីថ្មី។

### 8.4 ការងារបំពាក់កង្ហារ

ការងារកង្ហារជាប្រភេទកង្ហារជញ្ជាំង ម៉ាកហាតារីដោយរត់ប្រព័ន្ធខ្សែនៅលើពិដាន។

## 9 ការងារសម្អាតអាគារសាលប្រជុំចាស់

### 9.1 ការសម្អាតសាលប្រជុំ

សាលាប្រជុំចាស់ត្រូវបានបោះបង់ចោល និងត្រូវបានរៀបចំជួសជុលឡើងវិញ នៅពេលបន្ទាប់ សាលាប្រជុំនេះជាអាគាជាន់ផ្ទាល់ដី ដំបូលប្រក់ក្បឿងជញ្ជាំង ឥដ្ឋ មានសភាពចាស់ទ្រុឌទ្រោម និងមានសម្ភារៈបាក់បែកមួយចំនួននៅក្នុងបន្ទប់។ ចំពោះការងារនេះយើងត្រូវរុះរើដំបូលក្បឿងចាស់ដែលនៅសល់ពីបាក់បែក ប្រហែល ៥០% នៃទំហំដំបូលអាគាសរុប និងសម្អាតចេញពីអាគាទាំងអស់ ។ សម្អាតសម្ភារៈបាក់បែកទាំងអស់ចេញពីអាគា មានដូចជា គ្រោងដំបូល (ផ្ទោង ដែរណែង) ជញ្ជាំងបាក់បែក សាបបាក់បែក និងសម្ភារៈចាស់ៗផ្សេងទៀតដែលនៅក្នុងអាគា។








## តារាងសម្ភារៈ

| ល.រ | ទីតាំង/ឈ្មោះ | ប្រភេទ | ពណ៌ | រូបភាព | ទំហំ |
|---|---|---|---|---|---|
| | | | | | |
| 1 | ការងាររៀប ជញ្ជាំង,បេតុង-ល- | ស៊ីម៉ង់ត៍ អូដ្ឋ Camel ស៊ីម៉ង់ត៍ ខេ K-Cement | |  | 50គីឡូក្រាម/បាវ |
| 2 | ការងារបូក ជញ្ជាំង | ស៊ីម៉ង់ត៍ អូដ្ឋ Camel ស៊ីម៉ង់ត៍ ខេ K-Cement ខៀវ | |  | 50គីឡូក្រាម/បាវ |
| 3 | ការងារបេតុង ដែក | ដែកថ្នាំងអំពៅ SD 390 | |  | |
| 4 | ជញ្ជាំង | ម្សៅបៀក (Skim Coat) CamStar សញ្ញាផ្កាយ ១ ឬមានស | ស |  | 25គីឡូក្រាម/បាវ |
| 5 | ជញ្ជាំង | ថ្នាំទ្រនាប់ (Sealer) Cam paint ប្រូតាន់ | ស |  | 18 លីត/ធុង |
| 6 | ជញ្ជាំងក្រៅ | ថ្នាំស្រទាប់បញ្ចប់ CamPaint Vital | Code N3399 |  | 18 លីត/ធុង |

| | | | | | |
|---|---|---|---|---|---|
| 7 | ជញ្ជាំងក្នុង | ថ្នាំស្រទាប់បញ្ចប់ CamPaint Vital | ស |  | 18 លីត/ធុង |
| 8 | ពិដានក្នុងអាគារ | សន្លឹកពិដានធម្មតា ម៉ាក Elephant កម្រាស់ 9មម | ស |  | 1.2mx2.4m |
| 9 | ពិដានបន្ទប់ទឹក | សន្លឹកពិដានការពារសំណើម ម៉ាក Elephant កម្រាស់ 9 មម | ខៀវ |  | 1.2mx2.4m |
| 10 | ពិដាន | ឆ្អឹងពិដាន C-Line កម្រាស់ 0.27mm | ស |  | កម្រាស់ 0.27mm |
| 11 | ពិដាន | ថ្នាំ U-90 ពណ៌ស | ស |  | 18 លីត/ធុង |
| 12 | ផ្ទៃក្រៅអាគារ | ការ៉ូស្លួតខ្នាត 60x60 | ពណ៌ឈើស្រាល |  | 60cmx60cm |
| 13 | ផ្ទៃអាគារខាងក្នុង | ការ៉ូសាច់ម៉ាបកញ្ចក់ ៥ ជាន់ | ពណ៌សខ្មៅ | | 60cmx60cm |

| | | | | | | |
|---|---|---|---|---|---|---|
| 14 | ទ្វារកញ្ចក់មុខ | កញ្ចក់ឆ្អិន Glass Tempered 2សន្លឹក កម្រាស់ 12មម | ថ្លា |  | | |
| 15 | ទ្វារកញ្ចក់ | សោរ ដុំ ដៃទ្វារកញ្ចក់ ម៉ាក VVP Thai | អាលុយមីញ៉ូម |  | | |
| 16 | បណ្ណាល័យ | ការ៉ូឈើ ម៉ាក Calmax ឬ Kosmos កម្រាស់ 8 មម កញ្ចក់ | |  | | |
| 17 | ការងារអគ្គិសនី | អំពូលពិដានម៉ាក Egal ភ្លើង ៣ពណ៌ | ស |  | 18 វ៉ាត់ | |
| 18 | ការងារអគ្គិសនី | អំពូលពិដានម៉ាក Egal ភ្លើង ៣ពណ៌ | ស |  | 30 វ៉ាត់ | |
| 19 | ការងារអគ្គិសនី | អំពូលម៉ែត្រ LED ម៉ាក Egal ភ្លើងស | ស |  | 60 វ៉ាត់ 1.2m | |

| | | | | | | |
|---|---|---|---|---|---|---|
| 20 | ការងារអគ្គិសនី | ឌីសង់ទ័ម៉ាក Schneider, LS, Legrand | ស |  | | តាមទំហំត្រូវការ |
| 21 | ការងារអគ្គិសនី | ព្រីទេម៉ាក SGT | ស |  | | យកដូចរូប |
| 22 | ការងារអគ្គិសនី | កុងតាក់ម៉ា SGT | ស |   | | |
| 23 | ការងារអគ្គិសនី | ជើងព្រីម៉ាក SGT | ស |  | | |
| 24 | ការងារអគ្គិសនី | តែនម៉ាក ABC | ស |   | | |
| 25 | ការងារអគ្គិសនី | បំពង់ខ្សែភ្លើង | ស |  | | |
| 26 | ការងារអគ្គិសនី | ខ្សែភ្លើងម៉ាក Keystone Singapore | ក្រហម ខ្មៅ ទំហំតាមតម្រូវការ |  | | 100ម/ដុំ |

| | | | | | |
|---|---|---|---|---|---|
| 27 | បង្គន់នោម<br>Urinal<br>Cotto | Wall Hung Urinal<br>C313 Natasha<br>Urinal | Ceramic |  | W: 330 mm<br>H: 600 mm<br>L: 315 mm<br>Wei: 15 kilograms |